ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ៥៧១.......សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការទូទាត់បំណុលពន្ធ
# តាមរយៈកិច្ចព្រមព្រៀងទូទាត់ជាដំណាក់កាល

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលបានប្រកាស ឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើ និងតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានពន្ធដារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

### ប្រការ ១.-គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់វិធាននិងនីតិវិធីប្រមូលបំណុលពន្ធពីអ្នកជាប់ពន្ធ តាមរយៈកិច្ចព្រមព្រៀងទូទាត់ជាដំណាក់កាល ដើម្បីពង្រឹងការគ្រប់គ្រងបំណុលពន្ធនិងជាគុណប្រយោជន៍ដល់ថវិកាជាតិ។

### ប្រការ ២.-និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ÷

- ពាក្យ **"បំណុលពន្ធ"** សំដៅដល់ប្រាក់ពន្ធអាករគ្រប់ប្រភេទ ដែលអ្នកជាប់ពន្ធមិនបានបង់ នៅពេលដល់កំណត់ត្រូវបង់ រួមមានប្រាក់ពន្ធអាករ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវដែលទាក់ទិន។
- ពាក្យ **"ការទូទាត់ជាដំណាក់កាល"** សំដៅដល់ការទូទាត់បំណុលពន្ធ ទៅតាមដំណាក់កាលនីមួយៗ ដែលរដ្ឋបាលសារពើពន្ធបានអនុញ្ញាត។

### ប្រការ ៣.-លក្ខណៈវិនិច្ឆ័យ

ដើម្បីកំណត់ថាអ្នកជំពាក់បំណុលពន្ធណាមួយអាចទូទាត់បំណុលពន្ធជាដំណាក់កាលបាន អគ្គនាយកដ្ឋានពន្ធដារត្រូវ ÷

- ធ្វើការវិភាគលទ្ធភាពរបស់អ្នកជំពាក់បំណុលពន្ធថាមិនអាចទូទាត់បំណុលពន្ធតែមួយលើកបាន
- ពិនិត្យប្រវត្តិនៃការគោរពប្រតិបត្តិច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដាររបស់អ្នកជំពាក់បំណុលពន្ធ
- ពិនិត្យផ្ទៀងផ្ទាត់ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកជំពាក់បំណុលពន្ធ។

### ប្រការ៤.-សិទ្ធិសម្រេច

អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិសម្រេចលើសំណើសុំទូទាត់បំណុលពន្ធជាដំណាក់កាលៗ ដែលមានទឹកប្រាក់តិចជាង ឬស្មើនឹង ៤.០០០.០០០.០០០រៀល (បួនពាន់លានរៀល)។ ចំពោះសំណើសុំទូទាត់បំណុលពន្ធជាដំណាក់កាលៗដែលមានទឹកប្រាក់លើសពី ៤.០០០.០០០.០០០រៀល (បួនពាន់លានរៀល) អគ្គនាយកដ្ឋានពន្ធដារត្រូវស្នើសុំការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ប្រការ ៥.- ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

ដើម្បីសម្រេចលើកិច្ចព្រមព្រៀងទូទាត់បំណុលពន្ធជាដំណាក់កាល អ្នកជំពាក់បំណុលពន្ធត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចដូចតទៅ÷

- ពិនិត្យនិងផ្ទៀងផ្ទាត់សំណើសុំរបស់អ្នកជំពាក់បំណុលពន្ធ ដែលបានស្នើសុំទូទាត់ជាដំណាក់កាល
- ចុះត្រួតពិនិត្យផ្ទាល់ដល់គ្រឹះស្ថានអាជីវកម្មឬកន្លែងស្នាក់នៅរបស់អ្នកជំពាក់បំណុលពន្ធដែលជាកម្មវត្ថុនៃការស្នើសុំ។

**ប្រការ ៦.- ការអនុញ្ញាតកិច្ចព្រមព្រៀងទូទាត់បំណុលពន្ធជាដំណាក់កាល**

ផ្អែកតាមលទ្ធផលនៃការចុះពិនិត្យដូចមានចែងក្នុងប្រការ៥នៃប្រកាសនេះ ការអនុញ្ញាតលើកិច្ចព្រមព្រៀងទូទាត់បំណុលពន្ធជាដំណាក់កាល ត្រូវបានកំណត់ដូចខាងក្រោម÷

- រយៈពេលមិនលើសពី ៣ ឆ្នាំ
- ចំពោះការទូទាត់បំណុលពន្ធជាដំណាក់កាលៗក្នុងរយៈពេល១ឆ្នាំ ការប្រាក់ត្រូវបានលើកលែង
- ចំពោះការទូទាត់បំណុលពន្ធជាដំណាក់កាលៗលើសពីរយៈពេល១ឆ្នាំ ការប្រាក់ក្នុងរយៈពេល ១ឆ្នាំដំបូង ត្រូវបានលើកលែង ប៉ុន្តែនៅឆ្នាំទី២ ត្រូវបង់ការប្រាក់តាមអត្រាទីផ្សារដែលគណនាជាមធ្យមភាគដោយអគ្គនាយកដ្ឋានពន្ធដារ និងនៅឆ្នាំទី៣ ត្រូវបង់ការប្រាក់តាមអត្រា ២% ក្នុង១ខែ។

**ប្រការ ៧.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**÷

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ